ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

# របាយការណ៍

## ស្តីពី

## ការលក់កុមារ ពេស្យាកម្មកុមារ និងរូបភាព អាសអាភាសកុមារ

ខែតុលា ឆ្នាំ២០០៧

# មាតិកា


**សេចក្តីផ្តើម** ........................................ ១

I. **ស្ថាប័នរដ្ឋាភិបាល** ........................................ ១

II. **អង្គការមិនមែនរដ្ឋាភិបាល** ........................................ ២

III. **ព័ត៌មានលំអិតអំពីកម្មវិធី សកម្មភាព និងមធ្យោបាយ ដែលអនុវត្តដោយស្ថាប័នរាជរដ្ឋាភិបាល និងអង្គការនានា** ........................................ ២

IV. **ការលំបាក និងសំណូមពរ** ........................................ ១០


~~~~~~~~~~~~
~~~~~~~~~~~~

# សេចក្តីផ្តើម

ព្រះរាជាណាចក្រកម្ពុជាមានប្រពៃណីទំនៀមទម្លាប់ល្អក្នុងការគោរព និងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ។ រាជរដ្ឋាភិបាលកម្ពុជាបាននិងកំពុងយកចិត្តទុកដាក់ក្នុងការកាពារនិងលើកកម្ពស់សិទ្ធិសេរីភាព និងសេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋ។ អនុវត្តតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់និងបទដ្ឋានក្រោមច្បាប់ជាច្រើនត្រូវបានបង្កើតឡើង ដើម្បីធានាដល់ការរស់នៅប្រកបដោយសុវត្ថិភាព ជាពិសេសប្រឆាំងដាច់ខាតអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ អំពើអាសអាភាសដែលប៉ះពាល់ដល់សិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់ស្ត្រីនិងកុមារ។ កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលបានចែងអំពីការលើកកម្ពស់ការអនុវត្តសិទ្ធិជាមូលដ្ឋានទាំង៤របស់កុមារ ស្របទៅតាមអនុសញ្ញានៃអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ ដែលកម្ពុជាបានផ្តល់សច្ចាប័ន។ បច្ចុប្បន្ន រាជរដ្ឋាភិបាលបានបង្កើតគោលនយោបាយ ច្បាប់ ហើយមានកម្មវិធីនិងសកម្មភាពជាច្រើនត្រូវបានអនុវត្តដោយស្ថាប័នរាជរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលនានា និងទទួលបានលទ្ធផលដូចខាងក្រោម ៖

## I. ស្ថាប័នរាជរដ្ឋាភិបាល

- មានច្បាប់ជាតិ-អន្តរជាតិជាច្រើនដែលចែងពីការការពារសិទ្ធិសេរីភាពប្រជាពលរដ្ឋ ជាពិសេសច្បាប់ស្តីពីការបង្ក្រាបអំពើពង្រត់និងលក់ដូរមនុស្ស និងអំពើធ្វើអាជីវកម្មលើមនុស្ស (១៩៩៦)
- មានផែនការជាតិ៥ឆ្នាំប្រឆាំងការជួញដូរ និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ (២000-២00៤)
- បានចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយព្រះរាជាណាចក្រថៃឡង់ដ៏(២00៣)

ប្រទេសក្នុងមហាអនុតំបន់មេគង្គ (២00៤) និងសាធារណៈរដ្ឋសង្គមនិយមវៀតណាម(២00៥)

- បានបង្កើតក្រុមការងារថ្នាក់ជាតិ ដើម្បីអនុវត្តកិច្ចព្រមព្រៀងទ្វេភាគីនិងពហុភាគី អនុស្សរណៈនៃការយោគយល់គ្នារវាងរដ្ឋាភិបាលកម្ពុជានិងបណ្តាប្រទេសពាក់ព័ន្ធ ស្តីពីការលុបបំបាត់អំពើជួញដូរមនុស្ស និងជួយជនរងគ្រោះដោយសារការជួញដូរ(២00៧)
- បានបង្កើតក្រុមការងារថ្នាក់ជាតិ ដើម្បីប្រឆាំងនឹងអំពើជួញដូរមនុស្ស ការរត់ពន្ធ ការធ្វើអាជីវកម្ម ពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រីនិងកុមារ(២00៧)
- បានចុះកិច្ចព្រមព្រៀងស្តីពីគោលការណ៍ណែនាំអនុវត្ត និងកិច្ចសហការរវាងស្ថាប័នរាជរដ្ឋាភិបាលដែលពាក់ព័ន្ធនិងបណ្តាទីភ្នាក់ងារគាំទ្រជនរងគ្រោះ ក្នុងដំណើរការរឿងក្តីជួញដូរមនុស្ស(២00៧)
- មានកម្មវិធីស្តីពីការងារអនុវត្តច្បាប់ប្រឆាំងនឹងការរំលោភផ្លូវភេទ ការធ្វើអាជីវកម្មផ្លូវភេទ និងការជួញដូរស្ត្រីនិងកុមារ (LEASEC)
- មានកម្មវិធីបណ្តាញការពារកុមារតាមសហគមន៍ កម្មវិធីថែទាំជំនួសចំពោះកុមារ និងកម្មវិធីសមាហរណកម្មនិងតាមដាន

- មានគម្រោងកម្មវិធីទប់ស្កាត់ការជួញដូរស្ត្រីនិងកុមារនៅកម្ពុជា(២០០០-២០០៩)
- មានកម្មវិធីផ្សព្វផ្សាយ និងតាមដានការអនុវត្តច្បាប់
- មានកម្មវិធីលើកកម្ពស់ការយល់ដឹងដល់សិស្សសាលា អំពីសិទ្ធិកុមារ ការជួញដូរនិងកេងប្រវ័ញ្ចផ្លូវភេទ និង
- មានកម្មវិធីលើកកម្ពស់សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍។

## II. អង្គការមិនមែនរដ្ឋាភិបាល

- មានកម្មវិធីលុបបំបាត់ការជួញដូរនិងការធ្វើអាជីវកម្មផ្លូវភេទលើកុមារ និងគម្រោងកម្មវិធីធ្វើស្ថិតិរួមរបស់អង្គការមិនមែនរដ្ឋាភិបាល ស្តីពីការរំលោភនិងការជួញដូរកុមារនៅកម្ពុជា

- មានកម្មវិធីបណ្តាញភូមិសុវត្ថិភាព កម្មវិធីថែទាំជំនួសសម្រាប់កុមាររងគ្រោះ កម្មវិធីសមាហរណកម្ម កម្មវិធីជំរុញការអនុវត្តច្បាប់ កម្មវិធីការអប់រំសហគមន៍ឱ្យយល់ដឹងពីការជួញដូរ កម្មវិធីមិត្តអប់រំមិត្ត កម្មវិធីស្រង់ព័ត៌មាន និងទិន្នន័យ

- មានកម្មវិធីស្តារសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈរយៈពេលខ្លី/វែង បំណិនជីវិត និងសមាហរណកម្ម កម្មវិធីទាក់ទាញការគាំទ្រ និងស្រាវជ្រាវ កម្មវិធីអភិវឌ្ឍស្ថាប័ន និងធនធានមនុស្ស

- មានគម្រោងមហាអនុតំបន់មេគង្គ ប្រឆាំងការជួញដូរកុមារនិងស្ត្រី និង

- មានកម្មវិធីការពារកុមារ។

## III. ព័ត៌មានលំអិតអំពីកម្មវិធី សកម្មភាព និងមធ្យោបាយ ដែលអនុវត្តដោយស្ថាប័នរាជរដ្ឋាភិបាល និងអង្គការនានា

- រាជរដ្ឋាភិបាលមានគោលនយោបាយកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ហេតុនេះហើយ ក្រសួងយុត្តិធម៌បានរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ហើយដែលបានដាក់ឆ្លងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីរួចហើយ។

ដោយមានការឧបត្ថម្ភពីគម្រោង "កិច្ចសហប្រតិបត្តិការប្រចាំតំបន់អាស៊ីទប់ស្កាត់ការជួញដូរមនុស្ស"(ARCPPT) ក្រសួងយុត្តិធម៌បានបណ្តុះបណ្តាលចៅក្រម ព្រះរាជអាជ្ញា នគរបាល និងកងរាជអាវុធហត្ថ អំពីច្បាប់ទាក់ទងទៅនឹងការជួញដូរមនុស្ស និងជំនាញក្នុងការស៊ើបអង្កេត។ ដើម្បីពង្រឹងការអនុវត្តច្បាប់ ក្រសួងយុត្តិធម៌បានចេញសេចក្តីណែនាំលេខ ៩៧៨ ព្រ.ទ ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីគោលការណ៍បង្ក្រាបអំពើល្មើសច្បាប់មួយចំនួន និងសេចក្តីណែនាំលេខ ៧០០កយ ព្រ.ទ ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៥ ស្តីពីការចោទប្រកាន់ និងការផ្តន្ទាទោសជនប្រព្រឹត្តិបទល្មើសជួញដូរមនុស្ស និងធ្វើអាជីវកម្មផ្លូវភេទ។

- ផែនការជាតិប្រឆាំងការជួញដូរ និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារទី១(២០០០-២០០៤) មាន៤ផ្នែកគឺ កិច្ចបង្ការទប់ស្កាត់ កិច្ចការពារ ការកសាងសមត្ថភាព និងការធ្វើសមាហរណកម្ម ព្រមទាំង មានការបែងចែកភារកិច្ចទទួល

ខុសត្រូវដល់ក្រសួង ស្ថាប័នពាក់ព័ន្ធដើម្បីអនុវត្ត។ ការប៉ាន់ប្រមាណវាយតម្លៃលើការអនុវត្តផែនការនេះបានបង្ហាញឱ្យឃើញថា កម្ពុជាបានបោះជំហានទៅមុខគួរឱ្យកត់សំគាល់ជុំវិញការប្រយុទ្ធប្រឆាំងការជួញដូរនិងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ដោយមានកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធរវាងស្ថាប័នរាជរដ្ឋាភិបាល អង្គការនានា ក្នុងការដោះស្រាយបញ្ហា និង ការលំបាកចំពោះមុខ។ ផែនការទី១បានចប់អណត្តិ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារកំពុងកសាងផែនការជាតិទី២ (២០០៦-២០១០) ដោយផ្តោតលើកម្មវិធីចំនួន៥គឺ គោលនយោបាយនិងកិច្ចសហប្រតិបត្តិការ កិច្ចបង្ការទប់ស្កាត់ យុត្តិធម៌ព្រហ្មទណ្ឌ កិច្ចការពារការស្តារសម្បទានិងសមាហរណកម្ម និងកម្មវិធីពិសេស។

- ក្រុមការងារថ្នាក់ជាតិ ដើម្បីអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី និងពហុភាគី អនុស្សរណៈនៃការយោគយល់គ្នារវាងរាជរដ្ឋាភិបាលកម្ពុជា និងបណ្តាប្រទេសពាក់ព័ន្ធស្តីពីការលុបបំបាត់អំពើជួញដូរមនុស្ស និងជួយជនរងគ្រោះដោយសារការជួញដូរ ដែលដឹកនាំដោយក្រសួងកិច្ចការនារី បានផ្លាស់ប្តូរបទពិសោធន៍រវាងកម្ពុជា-វៀតណាម និងមានផែនការសកម្មភាពដើម្បីសហប្រតិបត្តិការបង្ក្រាប និងជួយជនរងគ្រោះនៃប្រទេសទាំង២ ដែលមានការឧបត្ថម្ភពីអង្គការយូនីសេហ្វ និងអង្គការទេសន្តប្រវេស្សន៍អន្តរជាតិ។ ក្រុមការងារនេះបានសម្របសម្រួលគម្រោងប្រឆាំងការជួញដូរមនុស្ស ដែលឧបត្ថម្ភថវិកាពីកម្មវិធីអភិវឌ្ឍន៍របស់សហរដ្ឋអាមេរិក(USAID)។ ទន្ទឹមនេះដែរ ដោយមានការឧបត្ថម្ភពីកម្មវិធីអន្តរភ្នាក់ងារអង្គការសហប្រជាជាតិប្រចាំកម្ពុជា(UNIAP) ក្រសួងកិច្ចការនារីបានសម្របសម្រួលក្រុមការងារខមមីតកម្ពុជាក្នុងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្សនៅមហាអនុតំបន់មេគង្គ។

- គណៈកម្មការអន្តរក្រសួង បង្ក្រាបបទល្មើស ភាពយន្ត និងវីដេអូ ក្នុងព្រះរាជាណាចក្រកម្ពុជា ដែលដឹកនាំដោយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បានសហការជាមួយអាជ្ញាធរដែនដីគ្រប់ខេត្ត-ក្រុង ទប់ស្កាត់ បង្ក្រាប និងដាក់ទណ្ឌកម្មចំពោះជនដែលលក់និងបញ្ចាំងកាសែតវីដេអូ វីស៊ីឌី ឌីវីឌី និងទស្សនាវដ្តីអាសអាភាសជាច្រើនលើក។

- ក្រុមការងារថ្នាក់ជាតិ ដើម្បីប្រឆាំងនឹងអំពើជួញដូរមនុស្ស ការរត់ពន្ធ ការធ្វើអាជីវកម្ម ពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រីនិងកុមារ ដែលដឹកនាំដោយឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងអំពើជួញដូរ រត់ពន្ធមនុស្ស ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ។ ក្រុមការងារបានចេញសេចក្តីសម្រេចលេខ ២៨១៥ ស.ស.រ ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០៧ បង្កើតលេខាធិការដ្ឋានមួយដែលមានសមាសភាពពីក្រសួងពាក់ព័ន្ធ ហើយដឹកនាំដោយអគ្គស្នងការរងនគរបាលជាតិមួយរូប។ លេខាធិការដ្ឋាននេះ មានភារកិច្ចជំនួយឱ្យក្រុមការងារថ្នាក់ជាតិក្នុងការតាមដាន ចាត់តាំងអនុវត្តយុទ្ធនាការតាមដានការអនុវត្តអនុស្សរណៈ កិច្ចព្រមព្រៀង សម្របសម្រួល និងសហការជាមួយតំណាងអង្គការជាតិ-អន្តរជាតិជំរុញការផ្សព្វផ្សាយផែនការយុទ្ធនាការ សម្របសម្រួលជាមួយស្ថាប័នតុលាការ និងធ្វើរបាយការណ៍រាល់៣ខែជូនក្រុមការងារថ្នាក់ជាតិ។

ក្រសួងមហាផ្ទៃបានបង្កើតនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ដែលមានការិយាល័យជំនាញនៅខេត្ត-ក្រុងចំនួន១៧ និងមានផ្នែកជំនាញនៅខេត្ត-ក្រុងចំនួន៧។ អង្គភាពទាំងនោះមានភារកិច្ចអនុវត្តច្បាប់

ដោយគោរពតាមនីតិវិធីក្នុងការស៊ើបអង្កេត ប្រមូលភ័ស្តុតាង ស្វែងរកចាប់ជនល្មើស។ ជាមួយនេះ ក្រសួងមហាផ្ទៃបានធ្វើផែនការសកម្មភាពលេខ០២៣នៅឆ្នាំ២០០៥ និងផែនការលេខ០១២នៅឆ្នាំ២០០៧។ ដោយមានកិច្ចសហការជាមួយអង្គការយូនីសេហ្វ និងអង្គការទស្សនៈពិភពលោក នាយកដ្ឋាននេះបានអនុវត្តកម្មវិធីស្តីពីការងារអនុវត្តច្បាប់ប្រឆាំងនឹងការរំលោភផ្លូវភេទ ការធ្វើអាជីវកម្មផ្លូវភេទ និងការជួញដូរស្ត្រីនិងកុមារ(LEASETC) ដោយបានបើកវគ្គបណ្តុះបណ្តាលគ្រូបង្គោលដល់ស្នងការរង មន្ត្រីនគរបាលជំនាញ និងមន្ត្រីនគរបាលឈរជើងនៅតាមព្រំដែននៃខេត្ត-ក្រុងចំនួន១៣ សរុបបានចំនួន ៦០០នាក់។ ការបណ្តុះបណ្តាលនេះសំដៅបង្កើនជំនាញស៊ើបអង្កេត ការស្វែងរកភ័ស្តុតាង ការជួយសង្គ្រោះ នីតិវិធីក្នុង ការសំភាសន៍ និងការកសាងសំណុំរឿងបញ្ជូនទៅតុលាការ។ ទន្ទឹមនេះដែរនាយកដ្ឋាននេះក៏បានផលិតខ្សែភាពយន្តដែលមានចំណង ជើងថា "ជនរងគ្រោះ" ហើយធ្វើការផ្សព្វផ្សាយតាមទូរទស្សន៍ជាតិកម្ពុជា។

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានកសាងផែនការសកម្មភាពដើម្បីជំរុញអង្គភាពជំនាញតាមខេត្ត-ក្រុងឱ្យអនុវត្តផែនការលេខ០២៣ របស់ក្រសួងមហាផ្ទៃឱ្យមានប្រសិទ្ធភាព។ ផែនការនោះមានវិធានការធំៗ៤គឺ ១-ការគ្រប់គ្រង និងតាមដានសភាពការណ៍ ២-ការបង្ការទប់ស្កាត់ ៣-ការបង្ក្រាប ៤-ការពង្រីកនិងពង្រឹងធនធានមនុស្ស។ នាយកដ្ឋាននេះមានទូរស័ព្ទពិសេស២៤ ម៉ោងលើ២៤ម៉ោង(HOTLINE) ដែលទទួលការហៅចូលបានពីរភាសា គឺខ្មែរនិងអង់គ្លេស ហើយបានទទួលការហៅចូលជាង៨០០លើកក្នុងមួយឆ្នាំៗ។ នៅឆ្នាំ២០០៥ ជនល្មើសចំនួន៤៣៤នាក់ត្រូវបានឃាត់ខ្លួន កុមាររងគ្រោះដែលមានអាយុក្រោម១៨ឆ្នាំចំនួន ៤៥៤នាក់ត្រូវបានសង្គ្រោះ។ ក្នុង៦ខែដើមឆ្នាំ២០០៦ បានបង្ក្រាប១៨៦ករណី ក្នុងនោះបានចាប់ជនសង្ស័យចំនួន ២១៤នាក់ និងបានសង្គ្រោះកុមារចំនួន១៤៩នាក់ លទ្ធផលនេះទទួលបានដោយសារមានការដឹកនាំល្អ ពីថ្នាក់ដឹកនាំនៃក្រសួងមហាផ្ទៃ អគ្គស្នងការនគបាលជាតិ និងការខិតខំរបស់មន្ត្រីអង្គភាពជំនាញប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនគ្រប់ជាន់ថ្នាក់ ពិសេសមានកិច្ចសហការល្អពីស្ថាប័នពាក់ព័ន្ធមាន ក្រសួងអប់រំ យុវជននិងកីឡា ក្រសួងកិច្ចការនារី ក្រសួងទេសចរណ៍ អាជ្ញាធរដែនដីក្នុងការផ្សព្វផ្សាយដល់សិស្ស ប្រជាពលរដ្ឋឱ្យយល់អំពីច្បាប់ ល្បិចកល និងសកម្មភាពរបស់ជនល្មើស ហើយពួកគេបានសហការផ្តល់ព័ត៌មានទាន់ពេលដើម្បីចាប់ខ្លួនជនល្មើស។ ក្នុងករណីជនល្មើសជាជនបរទេស នាយកដ្ឋានបានសហការជាមួយស្ថានទូត ឬស្ថានកុងស៊ុលប្រចាំនៅកម្ពុជា ដើម្បីនាំជននោះមកផ្តន្ទាទោស។

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានបង្កើតការិយាល័យប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្ម នៅឆ្នាំ២០០៦ ដើម្បីជួយជនរងគ្រោះនិងជនងាយរងគ្រោះដោយសារការជួញដូរ និងកេងប្រវ័ញ្ចផ្លូវភេទ ការរំលោភបំពាន និងជនរងគ្រោះដែលត្រូវបានធ្វើសមាហរណកម្មពីមណ្ឌលសង្គ្រោះនានា។ ក្រសួង ស.អ.យ បានចេញប្រកាសលេខ ២១៧ ស.អ.យ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០៦ ស្តីពីការដាក់ឱ្យអនុវត្តគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ ដែលផ្តោតលើការថែទាំទារកកំព្រាកុមារកំព្រា និងកុមារងាយរងគ្រោះដែលពុំស្ថិតនៅក្រោមការថែទាំរបស់ឪពុកម្តាយបង្កើត បច្ចុប្បន្នក្រសួង ស.អ.យ មានមណ្ឌលចំនួន២០នៅតាមខេត្ត-ក្រុង។ ដោយមានការឧបត្ថម្ភពីអង្គការយូនីសេហ្វ ក្រសួង ស.អ.យ បានបង្កើតកម្មវិធីបណ្តាញការពារកុមារតាមសហគមន៍នៅខេត្ត-

ក្រុងចំនួន៥ គឺភ្នំពេញ ខេត្តព្រៃវែង ស្វាយរៀង បាត់ដំបង និងបន្ទាយមានជ័យ។ បច្ចុប្បន្ន កម្មវិធីនេះកំពុងអនុវត្ត នៅ២ខេត្ត គឺព្រៃវែងនិងស្វាយរៀង ដើម្បីជាបទពិសោធន៍សម្រាប់ពង្រីកទូទាំងប្រទេស។ កម្មវិធីនេះធ្វើឱ្យភ្នាក់ងារអាជ្ញាធរដែនដី និងសហគមន៍បានធ្វើការរួមគ្នាដើម្បីកំណត់អត្តសញ្ញាណជនសង្ស័យ ហើយតាមដានសកម្មភាពជនទាំងនោះ។ ទន្ទឹមនេះដែរ កុមាររងាយរងគ្រោះមួយចំនួននៅតាមសហគមន៍ក៏ទទួលបានសេវាសង្គមកិច្ច ហើយមូលនិធិសង្គមកិច្ចត្រូវបានបង្កើតដើម្បីសង្គ្រោះបន្ទាន់ដល់កុមារងាយរងគ្រោះនៅក្នុងភូមិគោលដៅចំនួន៤០៨នៃខេត្តទាំង២។ កម្មវិធីនេះបានធ្វើការផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងដល់ប្រជាជននៅក្នុងភូមិចំនួន១៤.០៣៩ នៃ១៨៤ស្រុកទូទាំងប្រទេសលើប្រធានបទចំនួន៣គឺៈ ១-ការចុះអត្រានុកូលដ្ឋាន ២-ការប្រឆាំងការរំលោភបំពានផ្លូវភេទ ៣-ការប្រឆាំងការវាយដំលើកុមារ។

ដោយមានការឧបត្ថម្ភគាំទ្រទាំងផ្នែកបច្ចេកទេស និងថវិកាពីអង្គការយូនីសេហ្វ(UNICEF) និងអង្គការទេសន្តប្រវេស្សន៍អន្តរជាតិ(IOM) ក្រសួង ស.អ.យ បានធ្វើសមាហរណកម្មជនរងគ្រោះដោយសារការជួញដូរពីប្រទេសថៃចំនួន ១.២៧៦នាក់ (ឆ្នាំ២០០០ដល់២០០៦)។ ជនទាំងនោះត្រូវបានធ្វើការបញ្ជូនទៅតាមបណ្តាអង្គការជាដៃគូរ ដើម្បីស្តារសម្បទា និងបានផ្តល់សេវាផ្សេងៗទៀត។ កម្មវិធីធ្វើមាតុភូមិនិវត្តន៍នារីវៀតណាមដែលរងគ្រោះដោយការជួញដូរពីប្រទេសកម្ពុជាឱ្យត្រឡប់ទៅប្រទេសវៀតណាមវិញបានចំនួន៥៣នាក់។ ទន្ទឹមនេះក្រសួង ស.អ.យ បានរៀបចំច្បាប់ស្តីពីកូនអន្តរប្រទេសចប់សព្វគ្រប់ និងបានដាក់ជូនរដ្ឋសភាដើម្បីសុំការអនុម័ត។

- ក្រសួងកិច្ចការនារី បានសហការជាមួយក្រសួង និងអង្គការពាក់ព័ន្ធ អនុវត្តកម្មវិធីលើកកម្ពស់ការយល់ដឹងការផ្តល់ព័ត៌មានដែលគួរឱ្យទុកចិត្តបានពីការជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដល់ក្រុមដែលងាយរងគ្រោះ។ ចាប់ពីឆ្នាំ២០០៤ ដល់២០០៦ ដោយមានការឧបត្ថម្ភថវិកាពីរដ្ឋាភិបាលប្រទេសហ្វាំងឡង់ និងមានកិច្ចសហការជាមួយអង្គការទេសន្តប្រវេស្សន៍អន្តរជាតិ (IOM) ក្រសួងកិច្ចការនារីអនុវត្តសកម្មភាពសំខាន់ៗគឺ :

១-បណ្តុះបណ្តាលច្បាប់ដល់មន្ត្រីនៃក្រសួងស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋានក្នុងខេត្ត-ក្រុងចំនួន១៨ ដែលមានអ្នកចូលរួមចំនួន៣.២៤០នាក់ ។

២-ស្វែងរកមតិគាំទ្រនៅថ្នាក់ជាតិ លើការផ្តល់សច្ចាប័នលើពិធីសាររបស់អង្គការសហប្រជាជាតិ ការអនុម័តច្បាប់ប្រឆាំងការជួញដូរមនុស្ស ការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នារវាងកម្ពុជា-ថៃ និងកម្ពុជា-វៀតណាម ការធ្វើឱ្យប្រសើរឡើងនូវកម្រិតជីវភាពរបស់ប្រជាពលរដ្ឋ ដើម្បីកាត់បន្ថយភាពងាយរងគ្រោះដោយសារអំពើជួញដូរ។

៣-ធ្វើការផ្សព្វផ្សាយនៅក្នុងខេត្ត-ក្រុងចំនួន៦ ដែលមានអ្នកចូលរួមប្រមាណ១១២.៣៤០នាក់ តាមរយៈការបញ្ចាំងវីដេអូ ការសំដែងរឿងកំប្លែង ការធ្វើសំណួរ ការប្រជុំដោយមានចែកឯកសារ និងសម្ភារៈ ព្រមទាំងទម្រង់សម្រាប់មេភូមិប្រើប្រាស់នៅពេលមានហេតុការណ៍ក្នុងករណីជួញដូរមនុស្សកើតឡើង។ ទន្ទឹមនេះដែរ ក៏មានការផ្សព្វផ្សាយតាមវិទ្យុ និងទូរទស្សន៍ផងដែរ។

៤-អនុវត្តដកពិសោធន៍នូវកម្មវិធីមូលនិធិភូមិ ក្នុងភូមិចំនួន១០ នៃស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង។ មូលនិធិនេះមាន៣ផ្នែកគឺ មូលនិធិសង្គ្រោះបន្ទាន់ មូលនិធិភូមិ (ប្រាក់កម្ចី) និងការបណ្តុះបណ្តាលវិជ្ជាជីវៈដល់ក្រុមគ្រួសារ

ដែលជាមុខសញ្ញាងាយរងគ្រោះដោយសារការជួញដូរ ។

ចាប់ពីឆ្នាំ២០០៣ដល់២០០៦ ដោយមានការឧបត្ថម្ភថវិកាពីកម្មវិធីអភិវឌ្ឍន៍របស់សហរដ្ឋអាមេរិក(USAID) និងមានកិច្ចសហការជាមួយអង្គការ (IOM) ក្រសួងកិច្ចការនារីបានអនុវត្តគម្រោងផ្សព្វផ្សាយដើម្បីប្រយុទ្ធប្រឆាំងការជួញដូរស្ត្រីនិងកុមារ នៅក្នុងស្រុកចំនួន៧០ នៃខេត្តចំនួន ដែលមានអ្នកចូលរួមចំនួន៣០៥.០០០នាក់ ។

ចាប់ពីឆ្នាំ២០០៧ ដល់ឆ្នាំ២០០៩ ក្រសួងនឹងធ្វើសកម្មភាពក្នុងខេត្តគោលដៅចំនួន៥ ដោយផ្តោតលើផ្នែកសំខាន់ៗចំនួន៣ :

+ ការពង្រឹងកិច្ចសហប្រតិបត្តិការក្នុងតំបន់ដោយគាំទ្រដល់ការបង្កើត និងការអនុវត្តរបស់ក្រុមការងារថ្នាក់ជាតិ និងជំរុញការផ្សព្វផ្សាយនិងការអនុវត្តច្បាប់ជួញដូរថ្មី ។

+ សកម្មភាពទាក់ទងជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

+ ការកាត់បន្ថយភាពក្រីក្រក្នុងភូមិចំនួន១៣៥ នៃឃុំចំនួន២៧ ក្នុងស្រុកចំនួន៩ នៃខេត្តគោលដៅទាំង៥ និងបន្ត អនុវត្តសកម្មភាពដែលមានពីមុន ។

- ក្រសួងអប់រំ យុវជន និងកីឡា ធ្វើការផ្សព្វផ្សាយអំពីការជួញដូរមនុស្សដល់សិស្សសាលា តាមរយៈកម្មវិធីសិក្សាក្នុងនិងក្រៅប្រព័ន្ធ និងមានកម្មវិធីពិនិត្យតាមដានសុវត្ថិភាពកុមារតាមសាលា លើកកម្ពស់ការយល់ដឹងដល់សហគមន៍ឱ្យមានស្មារតីប្រុងប្រយ័ត្នការពារកុមាររួចផុតពីការជួញដូរ ។

- ក្រសួងទេសចរណ៍ បានចេញប្រកាសនិងសារាចរណែនាំជាច្រើន ដើម្បីទប់ស្កាត់ការកេងប្រវ័ញ្ច និងលុបបំបាត់អំពើពេស្យាចារនៅតាមមូលដ្ឋានអាជីវកម្ម សេវាកម្មទេសចរណ៍គ្រប់ប្រភេទ ព្រមទាំងមានវិធានការរដ្ឋបាលទៀតផង ។ ក្រសួងទេសចរណ៍បានបង្កើតគណៈកម្មាធិការសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍នៅឆ្នាំ២០០១ ដែលមានបណ្តាញនៅគ្រប់ខេត្ត-ក្រុង ក្នុងគោលបំណងរួមចំណែកទប់ស្កាត់ផលប៉ះពាល់ជាអវិជ្ជមានក្នុងវិស័យទេសចរណ៍ ពិសេសទេសចរណ៍ផ្លូវភេទលើកុមារនិងស្ត្រីវ័យក្មេង ។ គណៈកម្មាធិការនេះបានសហការជាមួយក្រសួង-ស្ថាប័ន និងអង្គការជាតិ-អន្តរជាតិពាក់ព័ន្ធមួយចំនួនធ្វើការបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិ ថ្នាក់ខេត្ត-ក្រុង និងថ្នាក់មូលដ្ឋាន ដល់មន្ត្រីរាជការ នគរបាល កងរាជអាវុធហត្ថ អាជ្ញាធរដែនដី ស្រុក ឃុំ ភូមិ មន្ទីរពាក់ព័ន្ធ និយោជិត-និយោជក នៅតាមបណ្តាមូលដ្ឋានអាជីវកម្ម សេវាកម្មទេសចរណ៍ គ្រូបង្រៀន សិស្សសាលា អំពីការលើកកម្ពស់សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ ដោយបានពន្យល់ អំពីនយោបាយទេសចរណ៍កម្ពុជា និងការចូលរួមចំណែកទប់ស្កាត់អំពីរបៀបទំនាក់ទំនងមកក្រសួងមានសមត្ថកិច្ចដើម្បីជួយជនរងគ្រោះឱ្យទាន់ពេលវេលា និងចាត់វិធានការទៅតាមផ្លូវច្បាប់ ។

នៅឆ្នាំ២០០៦ ក្រសួងទេសចរណ៍មានការបណ្តុះបណ្តាលអំពីការលើកកម្ពស់សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ ដល់កុមារចំនួន៤.០៦៥នាក់ និងមនុស្សពេញវ័យចំនួន១.៥៦៥នាក់ ហើយនៅ៦ខែ ដើមឆ្នាំ២០០៧ បានបណ្តុះបណ្តាលដល់មនុស្សពេញវ័យចំនួន៥៨៤នាក់ ។ ទន្ទឹមនេះដែរក៏ បានផលិតសម្ភារៈអប់រំផ្សព្វផ្សាយ ដូចជាស្លាកបិទសៀវភៅតូចៗ ផ្ទាំង រូបភាពខ្នាតតូច/ធំ ដើម្បីចែកចាយផ្សព្វផ្សាយតាមសហគមន៍ទេសចរណ៍ រមណីដ្ឋានទេសចរណ៍ និងនៅ

តាមខេត្ត-ក្រុង សំខាន់ៗមួយចំនួន។

ដោយមានជំនួយបច្ចេកទេស និងហិរញ្ញវត្ថុពីអង្គការពលកម្មអន្តរជាតិ/កម្មវិធីអន្តរជាតិស្តីពីការលុបបំបាត់ពលកម្មកុមារ ក្រសួងទេសចរណ៍បានកសាងនិងបោះពុម្ពសៀវភៅផែនការយុទ្ធសាស្ត្រ ២០០៧-២០០៩ ស្តីពីការលើកកម្ពស់សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ ដើម្បីទប់ស្កាត់ការជួញដូរកុមារនិងស្ត្រីក្នុងគោលបំណងកេងប្រវ័ញ្ចផ្លូវភេទ និងកម្លាំងពលកម្ម នៅក្នុងឧស្សាហកម្មទេសចរណ៍កម្ពុជា។ ក្រសួងទេចរណ៍បានបោះពុម្ភសៀវភៅគោលការណ៍ប្រតិបត្តិ សៀវភៅបណ្តុះបណ្តាល និងសៀវភៅឧបករណ៍សម្របសម្រួល សម្រាប់សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍។

ក្រសួងទេសចរណ៍ បានបង្កើតគណៈកម្មាធិការសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ ហើយគណៈកម្មការនេះនឹងបន្តធ្វើការអបរំបណ្តុះបណ្តាល ផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់ប្រជាជនគ្រប់រូប និងភ្ញៀវទេសចរនៅតាមតំបន់គោលដៅទេសចរណ៍ ជាពិសេស និស្សិតនៅតាមសកលវិទ្យាល័យ និងសិស្សនៅតាមវិទ្យាល័យ ទាំងផ្នែករដ្ឋ និងឯកជន ដើម្បីបញ្ជ្រាបបញ្ហានេះឱ្យដល់មូលដ្ឋាន។ បន្តពង្រឹងកិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័ន និងអង្គការជាតិ-អន្តរ ជាតិពាក់ព័ន្ធ សំដៅបង្កើនវិធានការអប់រំ និងវិធានការរដ្ឋបាលឱ្យមានប្រសិទ្ធភាព។

- ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ (ក.ជ.ក.ក) បានបង្កើតអនុគណៈកម្មការប្រឆាំងការជួញដូរ និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ និងបានផ្សព្វផ្សាយនិងជំរុញការងារប្រឆាំងការជួញដូរ និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ តាមរយៈការធ្វើសិក្ខាសាលានៅថ្នាក់ជាតិ និងខេត្ត-ក្រុង។ ក.ជ.ក.ក សហការជាមួយក្រសួង ស្ថាប័ន និងអង្គការនានា ធ្វើយុទ្ធនាការផ្សព្វផ្សាយ និងរៀបចំព្រឹត្តិការណ៍ផ្សេងៗ ដូចជាទិវាកុមារអន្តរជាតិ ១មិថុនា ជាដើម។ ដើម្បីជំរុញការចូលរួមរបស់កុមារ និងដោយមានការផ្តល់ថវិកាពីអង្គការនានា ក.ជ.ក.ក បានរៀបចំវេទិកាកុមារនៅថ្នាក់ជាតិជាច្រើនលើក ដែលមានកុមារមកពីខេត្ត-ក្រុងមួយចំនួនបានចូលរួម ដើម្បីស្តាប់មតិយោបល់ និងតម្រូវការរបស់កុមារ។ កុមារទាំងនោះបានលើកជាអនុសាសន៍ និងធ្វើសេចក្តីថ្លែងការណ៍ ដើម្បីជូនដល់ស្ថាប័នរាជរដ្ឋាភិបាល។ ក.ជ.ក.ក បានបញ្ជូនប្រតិភូកុមារទៅចូលរួមវេទិកាកុមារថ្នាក់តំបន់ជាច្រើនលើក។ ទន្ទឹមនេះ ក.ជ.ក.ក បានសម្របសម្រួលធ្វើសេចក្តីព្រាងផែនការជាតិប្រឆាំងការជួញដូរ និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ។

- គណៈកម្មាធិការបំបាត់ពេស្យាចារ ការរំលោភ និងជួញដូរកុមារនៅកម្ពុជា (ECPAT) ដែលមានអង្គការចំនួន២៧ជាសមាជិក បានចូលរួមអនុវត្តកម្មវិធីលើកកម្ពស់សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ជាមួយក្រសួងទេសចរណ៍។ គណៈកម្មាធិការនេះបានសម្របសម្រួលសកម្មភាពលុបបំបាត់ពេស្យាចារកុមារ រូបភាពអាសអាភាសកុមារ លើកកម្ពស់ការយល់ដឹង ការទាក់ទាញការគាំទ្រ ការត្រួតពិនិត្យតាមដាន ការចែកចាយព័ត៌មានដល់ស្ថាប័នពាក់ព័ន្ធ ការធ្វើ និងវិភាគស្ថិតិដែលមានសុពលភាពអាចជឿទុកចិត្តបាននៃកំណត់ត្រាករណីរំលោភសេពសន្ថវៈនិងជួញដូរ ការត្រួតពិនិត្យតាមដានការរីកចំរើន ការប្រែប្រួលក្នុងរយៈកាលប៉ុន្មានឆ្នាំខាងមុខ។ គណៈកម្មាធិការនេះបានអនុវត្តគម្រោង "ស្ថិតិរួមរបស់អង្គការនានាស្តីពីការរំលោភនិងការជួញដូរ" ដោយសហការជាមួយគណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាល ដើម្បីសិទ្ធិកុមារ ធ្វើការប្រមូលទិន្នន័យ វិភាគ និងបោះពុម្ពរបាយការណ៍ដើម្បីធ្វើការផ្សព្វផ្សាយ។ ព័ត៌មានទាំងឡាយ

គឺជាករណីដែលអង្គការជាសមាជិកបានផ្តល់សេវាដូចជា ការស៊ើបអង្កេត ការសង្គ្រោះ មណ្ឌលស្នាក់នៅ ឬផ្តល់ជំនួយផ្នែកច្បាប់។ របាយការណ៍នេះមានព័ត៌មានអំពីករណីរំលោភសេពសន្ថវៈចំនួន ៥៥៨ករណី និងករណីជួញដូរចំនួន ៧៦១ករណី។ ទិន្នន័យនេះមិនតំណាងឱ្យទូទាំងប្រទេសទេ គឺក្នុងក្របខ័ណ្ឌការផ្តល់សេវារបស់អង្គការដែលជាសមាជិកនៃគណៈកម្មាធិការទាំងពីរ។

- សម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលប្រឆាំងការជួញដូរកុមារនៅកម្ពុជា（Cambodia-ACTs） មានអង្គការចំនួន ១១ជាសមាជិក មានកម្មវិធីបណ្តាញភូមិសុវត្ថិភាព ដោយបានជំរុញឱ្យកុមារចូលរៀន លុបបំបាត់អំពើហិង្សា ល្បែងស៊ីសង។ កម្មវិធីថែទាំជំនួសសម្រាប់កុមាររងគ្រោះ ដែលអនុវត្តដោយអង្គការគាំពារកុមារដែលងាយទទួលរងគ្រោះ（VCAO） មានមណ្ឌលចំនួន៥ ដោយបានផ្តល់ការបណ្តុះបណ្តាលទៅតាមស្ថានភាពជាក់ស្តែងនៅក្នុងសហគមន៍របស់ពួកគេ។ កម្មវិធីនេះ បានជួយស្ត្រីនិងកុមាររងគ្រោះ ជាង៣០០នាក់នៅភ្នំពេញ ៣០០នាក់នៅខេត្តតាកែវ ១០០នាក់ខេត្តកណ្តាល ១០០នាក់ខេត្តសៀមរាប។ កម្មវិធីសមាហរណកម្មបានផ្តល់ប្រាក់កម្ចី ដើម្បីឱ្យប្រជាជនបង្កើតមុខរបរ។ កម្មវិធីជំរុញការអនុវត្តច្បាប់ កម្មវិធីអប់រំសហគមន៍ឱ្យយល់ដឹងពីការជួញដូរ កម្មវិធីមិត្តអប់រំមិត្ត កម្មវិធីស្រង់ព័ត៌មាន និងទិន្នន័យ។

- អង្គការដែលជាសមាជិកនៃសម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលដើម្បីដោះស្រាយបញ្ហាកេងប្រវ័ញ្ចផ្លូវភេទលើកុមារនៅកម្ពុជា（COSECAM）ដែលមានអង្គការចំនួន២២ជាសមាជិក បាននិងកំពុងអនុវត្តកម្មវិធីចម្បង ៣ ៖

+ បានធ្វើការលើកកម្ពស់ការយល់ដឹងអំពីសិទ្ធិកុមារ ការជួញដូរនិងកេងប្រវ័ញ្ចផ្លូវភេទ ដល់កុមារនិងប្រជាពលរដ្ឋក្រីក្រនៅតាមសហគមន៍មួយចំនួននៃខេត្ត-ក្រុងចំនួន៩ ដល់បុគ្គលិកជំនាញនៃស្ថាប័នរាជរដ្ឋាភិបាល និងអង្គការមួយចំនួនដល់សិស្សនៅតាមសាលាក្នុងនិងក្រៅប្រព័ន្ធ តាមរយៈបណ្ណាល័យចល័ត ការប្រជុំផ្សព្វផ្សាយ ការចែកខិតប័ណ្ណ ការបញ្ចាំងវីដេអូ ការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍។

+ បានធ្វើការបណ្តុះបណ្តាលវិជ្ជាជីវៈដល់កុមារក្រីក្រក្នុងសហគមន៍មួយចំនួន ដើម្បីឱ្យពួកគេមានមុខរបរ និងរួចផុតពីការជួញដូរ និងកេងប្រវ័ញ្ចផ្លូវភេទ។ ទន្ទឹមនេះ បានបណ្តុះបណ្តាលបុគ្គលិកនៃក្រសួង-ស្ថាប័នពាក់ព័ន្ធមួយចំនួនអំពីការស្តារសម្បទាដល់ជនរងគ្រោះ តួនាទីឪពុកម្តាយ ការគ្រប់គ្រងស្ថាប័ន ការគ្រប់គ្រងកម្មវិធី ការស៊ើបអង្កេត ការផ្តល់ប្រឹក្សាយោបល់ ការព្យាបាលផ្លូវចិត្ត ការដោះស្រាយជម្លោះ និងការតស៊ូមតិ។

+ បានផ្តល់ជម្រករយៈពេលខ្លីនិងវែងដល់ជនរងគ្រោះដែលបានសង្គ្រោះ និងបានផ្តល់សេវាផ្សេងៗ ដូចជាការព្យាបាលសុខភាព រាងកាយ និងផ្លូវចិត្ត ការបណ្តុះបណ្តាលវិជ្ជាជីវៈ រៀនអក្សរ បំណិនជីវិត។ ដើម្បីផ្តល់ឱកាសដល់កុមារឱ្យបានបញ្ចេញទស្សនៈ ការយល់ដឹង និងសំណូមពរ សម្ព័ន្ធនេះបានរៀបចំវេទិកាកុមារជាច្រើនលើក និងបានគាំទ្រឱ្យមានកម្មវិធីមិត្តអប់រំមិត្ត។

អង្គការមួយចំនួនបានរៀបចំឱ្យមានបណ្តាញការពារកុមារនៅតាមសហគមន៍ ដែលខ្លួនបានអនុវត្តកម្មវិធី និងមានការត្រួតពិនិត្យតាមដាន។ អង្គការមួយចំនួនបានចូលរួមការប្រជុំផ្តល់មតិយោបល់ក្នុងការងារកសាងច្បាប់ថ្មីៗដែល

ពាក់ព័ន្ធ និងកំណែទម្រង់ច្បាប់។ ធ្វើការស៊ើបអង្កេតករណីរំលោភបំពានលើកុមារ ធ្វើការផ្សព្វផ្សាយច្បាប់ដែលពាក់ព័ន្ធដល់ស្ថាប័នមួយចំនួន។

- គណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ (គ.អ.ស.ក) ដែលមានអង្គការចំនួន៤៦ជាសមាជិក បានរៀបចំពិធីផ្សេងៗ ក្នុងទិសដៅផ្សព្វផ្សាយបញ្ហាជួញដូរផ្លូវភេទ តាមរយៈការចងបដា កម្មវិធីសម្ដែងរឿងខ្លីៗ សំនួរ-ចម្លើយ និងចែកចាយខិតប័ណ្ណ ផ្ទាំងរូបភាព ដែលផលិតដោយអង្គការសមាជិក។ ក្រៅពីនេះ គ.អ.ស.ក បានសហការជាមួយបណ្ដាញអ៊ិកផាត និងកូសេកាំ លើការចងក្រងទិន្នន័យ រួមគ្នាស្ដីពីការរំលោភ និងជួញដូរផ្លូវភេទនៅកម្ពុជា។

- អង្គការអប់រំពិភពលោក និងអង្គការជាដៃគូ ដូចជាអង្គការឃែរ ខេប មិត្តសំឡាញ់ និងមូលនិធិអាស៊ី បានចុះអនុស្សរណៈជាមួយក្រសួងអប់រំ យុវជន និងកីឡា អនុវត្តកម្មវិធីអ៊ុបសិន នៅក្នុងខេត្តព្រៃវែង កំពង់ចាម បន្ទាយមានជ័យ និងភ្នំពេញ ដោយបានបង្កើន និងជំរុញការអប់រំប្រកបដោយសមធម៌ចំពោះកុមារី ដែលប្រឈមមុខនឹងគ្រោះថ្នាក់ និងការធ្វើអាជីវកម្មផ្លូវភេទ តាមរយៈកម្មវិធីអប់រំក្នុងនិងក្រៅប្រព័ន្ធ។ បានផ្សព្វផ្សាយនៅតាមសហគមន៍អំពីការជួញដូរ និងការធ្វើអាជីវកម្មផ្លូវភេទលើកុមារ និងជំរុញឱ្យមានការកែប្រែឥរិយាបទ ដើម្បីឱ្យកុមារ ជាពិសេសកុមារីក្នុងគ្រួសារដែលប្រឈមនឹងបញ្ហាសេដ្ឋកិច្ចបានចូលរៀន។ អង្គការនេះបានរៀបចំផែនការនៅថ្នាក់ឃុំ-សង្កាត់ ដើម្បីអនុវត្ត និងត្រួតពិនិត្យកិច្ចអន្តរាគមន៍គ្រប់លំដាប់ថ្នាក់។

- អង្គការពលកម្មអន្តរជាតិ/កម្មវិធីអន្តរជាតិស្ដីពីការលុបបំបាត់ពលកម្មកុមារ គម្រោងអនុតំបន់មេគង្គប្រឆាំងការជួញដូរកុមារនិងស្ត្រី (ILO/IPEC-TICW) បានធ្វើសកម្មភាពជាមួយស្ថាប័នរាជរដ្ឋាភិបាល សមាគមនិយោជក សហជីព អង្គការសហប្រជាជាតិ និងអង្គការមិនមែនរដ្ឋាភិបាល ក្នុងទិសដៅលុបបំបាត់ការធ្វើអាជីវកម្ម ការកេងប្រវ័ញ្ចផ្លូវភេទ និងពលកម្មលើស្ត្រីនិងកុមារ លើកកម្ពស់ការធ្វើចំណាកស្រុកដោយសុវត្ថិភាព តាមរយៈការកាត់បន្ថយភាពងាយរងគ្រោះ។ សកម្មភាពនេះបានអនុវត្តជាមួយជនដែលកំពុងរស់នៅកន្លែងគ្រោះថ្នាក់ជាងគេបំផុត ដែលអាចធ្វើឱ្យពួកគេធ្លាក់ខ្លួនជាជនរងគ្រោះដោយមិនដឹងខ្លួន ដោយប្រាប់ឱ្យពួកគេដឹងមុនអំពីគ្រោះថ្នាក់នៃការធ្វើចំណាកស្រុកដែលគ្មានព័ត៌មានច្បាស់លាស់ និងមិនបានរៀបចំទុកជាមុន។ អង្គការនេះបានជួយគាំទ្រស្ថាប័នរដ្ឋាភិបាលគ្រប់ជាន់ថ្នាក់ ដើម្បីអភិវឌ្ឍន៍ និងរក្សាការធ្វើចំណាកស្រុកដោយសុវត្ថិភាព ហើយបានផ្ដោតការយកចិត្តទុកដាក់ចំពោះកុមារ (កុមារានិងកុមារី)និងស្ត្រី ដែលមានជីវភាពខ្សត់ខ្សោយខ្វះការអប់រំរៀនសូត្រដែលងាយរងគ្រោះដោយការកេងប្រវ័ញ្ចផ្លូវភេទ និងពលកម្ម។ គម្រោងបានឧបត្ថម្ភគាំទ្រដល់កម្មវិធីជួយកុមារនិងស្ត្រីវ័យក្មេងងាយរងគ្រោះ ដើម្បីកែលំអគុណភាពជីវិតរបស់ពួកគេ។ សកម្មភាពសំខាន់ៗរបស់គម្រោងដែលផ្ដោតជាមូលដ្ឋានលើកុមាររួមមាន ការធ្វើអន្តរាគមន៍ពហុថ្នាក់ (ថ្នាក់ជាតិរហូតដល់មូលដ្ឋាន) កិច្ចសហប្រតិបត្តិការអន្តរស្ថាប័ន ការចែករំលែកព័ត៌មាន ការបញ្ជ្រាបយេនឌ័រ ការចូលរួមរៀបចំផែនការជាតិ និងផែនការខេត្ត ការបង្កើតនិងពង្រឹងយន្តការការពារក្រុមងាយរងគ្រោះ ការកសាងសមត្ថភាព ការលើកកម្ពស់ការយល់ដឹង ការរៀបចំវេទិកាកុមារយុវជន ការអប់រំក្រៅប្រព័ន្ធ ការបណ្ដុះបណ្ដាលជំនាញទៅដល់ជនបទ

ឥណទាន ការបង្កើនប្រាក់ចំណូល ការរៀបចំសិក្ខាសាលាថ្នាក់ជាតិ/ខេត្ត ការពិនិត្យតាមដាននិងវាយតម្លៃលើសកម្មភាពគម្រោងដោយមានការចូលរួម ការសិក្សាស្រាវជ្រាវ ការប្រមូលព័ត៌មានទិន្នន័យអំពីការជួញដូរ និងការផ្សព្វផ្សាយ ។

- អង្គការយូនីសេហ្វមានកម្មវិធីការពារកុមារ ដែលធ្វើសកម្មភាពជាពិសេសសំដៅពង្រឹងកិច្ចការពារ ទាំងខាងផ្នែកសង្គម និងផ្លូវច្បាប់ ចំពោះកុមារដែលងាយរងគ្រោះជាងគេនៅក្នុងសង្គម ដូចជាកុមារដែលមិនបានទទួលការថែរក្សាផ្ទាល់ពីមាតាបិតាបង្កើត និងកុមារដែលរងគ្រោះដោយអំពើហិង្សាផ្សេងៗរួមទាំងការជួញដូរនិងអាជីវកម្មផ្លូវភេទ កុមារទំនាស់នឹងច្បាប់ និងកុមារពិការ។ ជាមួយនឹងការទាក់ទាញការគាំទ្រឱ្យរាជរដ្ឋាភិបាល រៀបចំបង្កើតច្បាប់និងលិខិតបទដ្ឋានផ្សេងៗដែលទាក់ទងទៅនឹងកិច្ចការពារកុមារ កម្មវិធីនេះបានជួយកសាងសមត្ថភាពមន្ត្រីរបស់រាជរដ្ឋាភិបាលអំពីនីតិវិធីក្នុងកិច្ចការការពារកុមារ (ការបណ្តុះបណ្តាលមន្ត្រីនគរបាលតាមរយៈគម្រោងការ "ការអនុវត្តច្បាប់ប្រឆាំងនឹងការធ្វើអាជីវកម្ម ការកេងប្រវ័ញ្ចផ្លូវភេទ និងការជួញដូរកុមារ" ការបណ្តុះបណ្តាលចៅក្រម និងព្រះរាជអាជ្ញាខេត្ត-ក្រុង អំពីសិទ្ធិកុមារ ។ល ។) និងអំពីរបៀបផ្តល់សេវាជួយកុមារដែលរងគ្រោះ (ការបណ្តុះបណ្តាលមន្ត្រីសង្គមកិច្ចអំពីសេវាសង្គមកិច្ចមូលដ្ឋាន និងជំនាញ) ។ កម្មវិធីការពារកុមារក៏ផ្តល់ការគាំទ្រផងដែរដល់អង្គការមិនមែនរដ្ឋាភិបាលមួយចំនួនដើម្បីឱ្យផ្តល់សេវាផ្ទាល់ដល់កុមារដែលត្រូវការកិច្ចការពារពិសេស ។

- អង្គការកម្មវិធីអន្តរភ្នាក់ងារអង្គការសហប្រជាជាតិ ប្រឆាំងអំពើជួញដូរមនុស្សអនុតំបន់ទន្លេមេគង្គ (UNIAP) បានជួយឧបត្ថម្ភដល់ក្រុមការងារខមមីតកម្ពុជា ក្នុងការអនុវត្តភារៈកិច្ចនិងផែនការសកម្មភាពរបស់ខ្លួន បានចូលរួមការងារធ្វើផែនការជាតិ បានជួយគាំទ្រការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នា បានរៀបចំប្រព័ន្ធទិន្នន័យស្តីពីអង្គការនិងកម្មវិធីដែលប្រឆាំងការជួញដូរមនុស្ស បានសម្របសម្រួលឱ្យមានកិច្ចប្រជុំផ្លាស់ប្តូរព័ត៌មានរវាងស្ថាប័នពាក់ព័ន្ធ ព្រមទាំងបានឧបត្ថម្ភដល់ការកសាងសមត្ថភាពជូនដល់មន្ត្រី-បុគ្គលិកនៃក្រសួងនិងអង្គការ ដែលធ្វើការងារប្រឆាំងការជួញដូរមនុស្ស ។

## IV. ការលំបាក និងសំណូមពរ

- ប្រទេសកម្ពុជាទើបឆ្លងផុតសង្គ្រាមនិងរបបប្រល័យពូជសាសន៍ ដែលអត្រាភាពក្រីក្រ និងភាពងាយរងគ្រោះនៅមានកម្រិតខ្ពស់នៅឡើយ ។

- ប្រជាជនមួយចំនួនមានកម្រិតវប្បធម៌ទាប ធ្វើឱ្យការយល់ដឹងអំពីច្បាប់ និងបញ្ហាជួញដូរនៅមានកម្រិត ។ ការធ្វើចំណាកស្រុកដោយប្រថុយប្រថាននៅតែកើតមាន ដោយសារខ្វះខាតជីវភាព ។

- ការផ្សព្វផ្សាយ ការអនុវត្តច្បាប់នៅមានកម្រិត ។

- ស្ថាប័នរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល នៅមានកង្វះខាតធនធានមនុស្ស និងមធ្យោបាយ ។

- កិច្ចសហការរវាងស្ថាប័នពាក់ព័ន្ធនៅមានកម្រិត ។ កិច្ចសហការរវាងជនរងគ្រោះជាមួយអាជ្ញាធរមានសមត្ថកិច្ចមិនទាន់បានល្អ ។

ដើម្បីបំពេញកង្វះខាតខាងលើ រាជរដ្ឋាភិបាលបាន និងកំពុងរិះរកយុទ្ធសាស្ត្រ និងវិធានការគ្រប់បែបយ៉ាង ដើម្បីដោះស្រាយបញ្ហានេះឱ្យបានល្អ។

- សំណូមពរ សូមអង្គការសហប្រជាជាតិ និងដៃគូរអភិវឌ្ឍន៍នានា ផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសដល់កម្ពុជាឱ្យបានច្រើនថែមទៀត និងសូមឱ្យអង្គការសហប្រជាជាតិរៀបចំពង្រឹងយន្តការអន្តរជាតិ និងតំបន់ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការផ្នែកច្បាប់ឱ្យគ្នាទៅវិញទៅមក ឱ្យកាន់តែល្អប្រសើរថែមទៀត។

~~~~~~~~~~~
~~~~~~~~~~~